# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ផ្សព្វផ្សាយបន្ទាន់

ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០

## **កម្ពុជា៖ សាលាឧទ្ធរណ៍ប្រទេសថៃនឹងចេញសេចក្តីសម្រេចលើបណ្តឹងជាសមូហភាពឆ្លងដែនដំបូងបង្អស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចំពោះការរំលោភបំពានសិទ្ធិមនុស្ស**

*តើតុលាការថៃនឹងប្រកាន់ខ្ជាប់នូវបទដ្ឋានធុរកិច្ច និងសិទ្ធិមនុស្សដូចដែលបានណែនាំដោយគណៈ កម្មាធិការសិទ្ធិមនុស្សជាតិថៃ និងផែនការសកម្មភាពជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្សដែរឬទេ ?*



**នៅថ្ងៃសុក្រទី៣១ ខែកក្កដា ឆ្នាំ ២០២០** តុលាការ រដ្ឋប្បវេណីក្រុងបាងកកខាងត្បូងនឹងចេញសេចក្តីសម្រេចជាប្រវត្តិសាស្ត្រលើបណ្តឹងឧទ្ធរណ៍ស្នើសុំ ឋានៈជា **បណ្តឹងសហមូហភាព** នៅក្នុងរឿងក្តីរបស់លោកស្រី ហូយ ម៉ៃ និងជនរងគ្រោះផ្សេងទៀត ជាមួយនឹងក្រុមហ៊ុន **មីត្រផូល ខូអិលធីឌី (Mitr Phol Co., Ltd)**។ បណ្តឹងជាសមូហភាពឆ្លងដែននេះ គឺជាបណ្តឹងដំបូងគេនៅតំបន់អាស៊ីអាគ្នេយ៍ ដែលពាក់ព័ន្ធរវាងកសិកររងគ្រោះនៅកម្ពុជាជាមួយនឹងក្រុមហ៊ុនពហុជាតិដ៏ធំរបស់ប្រទេសថៃ។ ករណីនេះនឹងកំណត់ពីសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ដើមបណ្តឹងនៅក្នុងប្រព័ន្ធយុត្តិធម៌របស់ថៃ និងគណនេយ្យភាពសាជីវកម្មនៅក្នុងតំបន់ផងដែរ។ រឿងនេះប្រៀបដូចករណីរឿង ដេវីឌ (David) និង កូលីយ៉េត (Goliath) *ផងដែរ (រឿងបុរសតូច ដែលបានប្រយុទ្ធតទល់នឹងយក្សដ៏ធំសម្បើម នៅក្នុងរឿងទេវកថា របស់អង់គ្លេស)*

ក្នុងអំឡុងឆ្នាំ២០០៨ រហូតដល់ឆ្នាំ២០០៩ ដើមបណ្តឹង អ្នកស្រី ហូយ ម៉ៃ និងលោក ស្មិន តិត ត្រូវបានបណ្តេញចេញដោយបង្ខំពីដីរបស់ពួកគាត់ នៅក្នុងប្រទេសកម្ពុជាដើម្បីយកដីទាំងនោះមកដាំអំពៅ ដោយក្រុមហ៊ុន មីត្រផូល (Mitr Phol)[i] ដែលជាក្រុមហ៊ុនផលិតស្ករសធំបំផុតនៅក្នុងតំបន់អាស៊ី។ ផ្ទះនិងទ្រព្យសម្បត្តិរបស់ដើមបណ្តឹងត្រូវបានដុតបំផ្លាញចោល ហើយប្រជាពលរដ្ឋរងគ្រោះត្រូវបានគំរាមកំហែងដោយប្រើអំពើហឹង្សាលើរូបរាងកាយ និងចាប់ដាក់ពន្ធនាគារនៅពេលដែលពលរដ្ឋធ្វើការតវ៉ានឹងក្រុមហ៊ុន។ អ្នកស្រី ហូយ ម៉ៃ

---

[i] http://www.bankokpost.com/business/1555034/mitr-phol-targets-q4-opening-in-china

បានជាប់ពន្ធនាគារអស់រយៈពេល ០៨ខែ រហូតដល់គាត់សម្រាលបានកូនប្រុសម្នាក់។ ចំពោះ អ្នកស្រីហួយ ម៉ៃ និងលោក ស្មិន តិត បណ្តឹងជាសមូហភាពនេះគឺជាឱកាសតែមួយគត់ដើម្បីទទួលបានយុត្តិធម៌ពីការរំលោភសិទ្ធិមនុស្ស សម្រាប់ក្រុមពលរដ្ឋរងគ្រោះក្នុងសហគមន៍ជាង៧០០គ្រួសារ ដែលអ្នកស្រីហួយ ម៉ៃ និងលោក ស្មិន តិត តំណាងឱ្យ។

*“ឋានៈជា បណ្តឹងសមូហភាព គឺមានការចាំបាច់ដើម្បីការពារសិទ្ធិរបស់ប្រជាជនកម្ពុជាដែលងាយរងគ្រោះទាំងនេះ។ ការផ្តល់នូវឋានៈប្រភេទនេះ នឹងក្លាយជាគំរូផ្លូវច្បាប់ដ៏រឹងមាំមួយដែលបង្ហាញថាក្រុមហ៊ុនសាជីវកម្មធំៗនឹងត្រូវទទួលខុសត្រូវចំពោះព្យសនកម្មទាំងឡាយដែលបណ្តាលមកពីប្រតិបត្តិការរបស់ខ្លួនមិនថានៅទីណានោះទេ”* នេះបើតាមប្រសាសន៍របស់**លោក អៀង វុទ្ធី** នាយកប្រតិបត្តិអង្គការសមធម៌កម្ពុជា ។

សម្រាប់ប្រទេសថៃ និងតំបន់អាស៊ីអាគ្នេយ៍ បណ្តឹងសមូហភាព និងការអនុវត្តចំពោះបណ្តឹងប្រភេទនេះ ក្នុងការធ្វើបណ្តឹងឆ្លងដែន ដើម្បីការពារសិទ្ធិរបស់ក្រុមជនងាយរងគ្រោះបំផុតមួយចំនួននៅក្នុងតំបន់គឺ ការសាកល្បងថ្មីមួយ។ ករណីនេះនឹងកំណត់អំពីការប្តេជ្ញាចិត្តរបស់ប្រទេសថៃចំពោះផែនការសកម្មភាពជាតិ ស្តីពីធុរកិច្ច និងសិទ្ធិមនុស្សដែលបានចែងយ៉ាងច្បាស់ពីការផ្តល់សិទ្ធិក្នុងការទទួលបានយុត្តិធម៌នៅក្នុងប្រទេសថៃ រួមទាំងសិទ្ធិក្នុងការទទួលបានដំណោះស្រាយ និងកិច្ចការពារដែលទាក់ទងនឹងប្រតិបត្តិការឆ្លងដែន។

*(ដំណើររឿងនៃបណ្តឹងសមូហភាពនេះអាចរកបាននៅគេហទំព័រ Al Jazeera និងគេហទំព័រគណៈកម្មាធិការសិទ្ធិមនុស្សជាតិថៃ។)*

*“រឿងក្តីនេះគឺជាការសាកល្បងដ៏ពិតប្រាកដមួយថា តើប្រព័ន្ធយុត្តិធម៌របស់ប្រទេសថៃគឺគ្រាន់តែសម្រាប់រឿងក្តីក្នុងស្រុក ឬសម្រាប់មនុស្សគ្រប់គ្នាដែលស្វែងរកយុត្តិធម៌ រួមទាំងករណី បណ្តឹងឆ្លងដែនផងដែរ។ ករណីនេះជាឱកាសមួយសម្រាប់ប្រទេសថៃដើម្បីបង្ហាញដល់ប្រជាជនថៃ និងសហគមន៍អន្តរជាតិថាប្រទេសថៃនឹងលើកស្ទួយសិទ្ធិមនុស្ស ក៏ដូចជាសេចក្តីថ្លៃថ្នូរ និងតម្រូវការសម្រាប់ការប្រតិបត្តិធុរកិច្ចល្អបំផុត”* នេះបើតាមលោកស្រីមេធាវី **Sor.Rattanamanee Polkla** ដែលជាមេធាវីរបស់មជ្ឈមណ្ឌលធនធានសហគមន៍។

ការបើកសវនការសម្រេចនឹងធ្វើឡើងនៅ៖

**ម៉ោង ៩ ព្រឹក ថ្ងៃសុក្រទី ៣១ ខែកក្កដា**

តុលាការរដ្ឋប្បវេណីបាងកកខាងត្បូង

**ព័ត៌មានលំអិតសូមទាក់ទង៖**

- លោក អៀង វុទ្ធី នាយកប្រតិបត្តិអង្គការ សមធម៌កម្ពុជា

  **អ៊ីម៉ែល៖** vuthy@equitablecambodia.org **ទូរសព្ទ៖** +855 23 210 508

- លោកស្រី Sor.Rattanamanee Polkla មន្ត្រីសម្របសម្រួលប្រតិបត្តិនៃមូលនិធិមជ្ឈមណ្ឌលធនធានសហគមន៍ (CRC)

  **អ៊ីម៉ែល៖** sorrattana1@gmail.com **ទូរសព្ទ៖** +66817725843

- លោក Melissa Ananthraj ប្រធានកម្មវិធីទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយ វេទិកាអាស៊ី

  **អ៊ីម៉ែល៖** communication@forum-asia.org

កំណត់សម្គាល់៖ ខណៈដែលមានការដាក់បម្រាមដោយសារជំងឺ Covid-19 ដើមបណ្តឹងនឹងមិនបានចូលរួមក្នុងសវនាការនោះទេ ប៉ុន្តែអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសថៃ និងភាគីពាក់ព័ន្ធផ្សេងទៀតនឹងមានវត្តមាន។ ដើមបណ្តឹង និងអង្គការសង្គមស៊ីវិលកម្ពុជាអាចទំនាក់ទំនងបានតាមរយៈទូរសព្ទ។